**សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង**

# វ៉ាក់សាំងវ៉ារីសេឡា (ជំងឺអុតស្វាយ)៖

## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**វ៉ាក់សាំងវ៉ារីសេឡា** (Varicella) អាចបង្ការ **ជំងឺអុតស្វាយ**។

**ជំងឺ អុតស្វាយ** បណ្តាលឱ្យមានកន្ទួលរមាស់រយៈពេលប្រហែលមួយសប្តាហ៍ ។ ជំងឺ នេះអាចបណ្តាលឱ្យក្តៅខ្លួន អស់កម្លាំង បាត់បង់ចំណង់ អាហារ និងឈឺក្បាល។ ជំងឺអុតស្វាយអាចនាំឱ្យមានការឆ្លងមេរោគលើស្បែក ឆ្លងមេរោគសួត រលាកសរសៃឈាម ហើមខួរក្បាល និង/ឬខួរឆ្អឹងខ្នង និងការឆ្លងមេរោគចូលឈាម ឆ្អឹង ឬសន្លាក់។ អ្នកខ្លះមានជំងឺ អុតស្វាយមានកើតកន្ទួល ឈឺ ចាប់ដែលជាច្រើនឆ្នាំកន្លងមកគេហៅថា “ជំងឺរើម” (ស្គាល់ថាជាវីរុសប៉េស)។

ជំងឺ អុតស្វាយជាទូទៅមានកម្រិតស្រាលប៉ុន្តែវាអាចធ្ងន់ធ្ងរចំពោះទារកដែលមានអាយុក្រោម 12 ខែ ក្មេងជំទង់ មនុស្សពេញវ័យ អ្នកមានផ្ទៃពោះ និងអ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ។ មនុស្សមួយចំនួនឈឺដែលត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ វាមិនកើតឡើងញឹកញាប់ទេ ប៉ុន្តែមនុស្សអាចស្លាប់ដោយសារជំងឺអុតស្វាយបាន។

មនុស្សភាគច្រើនដែលបានចាក់វ៉ាក់សាំងវ៉ារីសេឡា 2 ដូស នឹងត្រូវបានការពារអស់មួយជីវិត។

## 2. វ៉ាក់សាំងវ៉ារីសេឡា

**កុមារ** ត្រូវការវ៉ាក់សាំងវ៉ារីសេឡា 2 ដូស ជាធម្មតា៖
- ការចាក់វ៉ាក់សាំងដូសដំបូង នៅអាយុ 12 ទៅ 15 ខែ
- ការចាក់វ៉ាក់សាំងដូសទីពីរ៖ នៅអាយុ 4 ឆ្នាំ ទៅ 6 ឆ្នាំ

**កុមារដែលមានអាយុច្រើនជាងនេះ ក្មេងជំទង់** និង **មនុស្សពេញវ័យ** ក៏ត្រូវការវ៉ាក់សាំងវ៉ារីសេឡាចំនួន 2 ដូសផងដែរ ប្រសិនបើពួកគេមិនទាន់មានភាពស៊ាំនឹងជំងឺ អុតស្វាយ។

វ៉ាក់សាំងវ៉ារីសេឡាអាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។ ដូចគ្នានេះផងដែរ ក្មេងអាយុចន្លោះពី 12 ខែដល់ 12 ឆ្នាំអាចទទួលបានវ៉ាក់សាំងវ៉ារីសេឡា រួមគ្នាជាមួយនឹងវ៉ាក់សាំង MMR (កញ្ជ្រឹល ស្រឡទែន និងស្អូច) ក្នុងការចាក់តែម្តង ឬហៅថា MMRV។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

## 3. និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកដើម្បីស្វែងយល់បន្ថែមទៀត។

ប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក ប្រសិនបើ បុគ្គលនោះទទួលវ៉ាក់សាំង៖
- មាន **ប្រតិកម្មអាឡែហ្សី បន្ទាប់ពី ការ ទទួលវ៉ាក់សាំងវ៉ារីសេឡាមុនៗ** ឬមាន **អាឡែហ្សី ធ្ងន់ធ្ងរគំរាមកំហែងដល់ជីវិត**
- **ស្ត្រី មានផ្ទៃពោះ** ឬ គិតថាពួកគេអាចនឹងមាន ផ្ទៃពោះ—ស្ត្រី មានផ្ទៃពោះមិនគួរទទួលវ៉ាក់សាំងវ៉ារីសេឡានោះទេ
- មាន **ប្រព័ន្ធការពាររាងកាយចុះខ្សោយ** ឬមាន **ឪពុកម្តាយ បងប្អូនប្រុស ឬស្រី ដែលមានប្រវត្តិ ទាក់ទងនឹង បញ្ហាប្រព័ន្ធការពារ រាងកាយពីកំណើត ឬតំណពូជ**
- **កំពុងតែប្រើ** Salicylates (ដូចជាថ្នាំអាស្ពីរីន)
- ថ្មីៗនេះ**មានការបញ្ចូលឈាម ឬទទួលបានផលិតផលឈាមដទៃទៀត**
- **មានជំងឺ របេង**
- **ទទួលវ៉ាក់សាំងផ្សេងទៀតក្នុងរយៈពេល 4 សប្តាហ៍**

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចចិត្តពន្យារពេលការចាក់វ៉ាក់សាំងវ៉ារីសេឡារហូតដល់ការណាត់ជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន។ អ្នកដែលមានជំងឺ ធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំងវ៉ារីសេឡា។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4. ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

- អការៈឈឺ ដៃដោយសារការចាក់ ឡើងក្រហម ឬកន្ទួលនៅកន្លែង ចាក់ថ្នាំ ឬគ្រុនក្តៅអាចកើតឡើងបន្ទាប់ពីចាក់វ៉ាក់សាំង វ៉ារីសេឡា។
- ប្រតិកម្មធ្ងន់ធ្ងរជាងនេះកើតឡើងកម្រណាស់។ ទាំងនេះអាចរួមមានជំងឺរលាកសួត ការឆ្លងមេរោគនៃខួរក្បាល និង/ឬការគ្របខួរឆ្អឹងខ្នង ឬការប្រកាច់ដែលច្រើនតែបណ្តាលមកពីគ្រុនក្តៅ។
- ចំពោះអ្នកដែលមានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងប្រព័ន្ធការពាររាងកាយ វ៉ាក់សាំងនេះអាចបណ្តាលឱ្យឆ្លងដែលអាចគំរាមកំហែងដល់អាយុជីវិត។ អ្នកដែលមានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងប្រព័ន្ធការពាររាងកាយ មិនគួរទទួលថ្នាំបង្ការជំងឺ វ៉ារីសេឡាទេ។

អ្នកដែលទទួលថ្នាំបង្ការអាចកើតកន្ទួលរមាស់។ ប្រសិនបើករណីនេះកើតឡើង មេរោគវ៉ាក់សាំងវ៉ារីសេឡា អាចឆ្លងទៅមនុស្សដែលគ្មានការការពារ។ អ្នកដែលកើតកន្ទួលគួរនៅឆ្ងាយពីអ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និងទារកដែលមិនទាន់ចាក់វ៉ាក់សាំងរហូតទាល់តែបាត់កន្ទួល។ និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកដើម្បីស្វែងយល់បន្ថែមទៀត។

មនុស្សមួយចំនួនដែលទទួលថ្នាំបង្ការជំងឺអុតស្វាយ អាចកើតជំងឺរើម (herpes zoster) ប៉ុន្មានឆ្នាំក្រោយមក។ នេះគឺជាបញ្ហាកម្រកើតមានក្រោយពេលចាក់ថ្នាំបង្ការជាងក្រោយកើតជំងឺអុតស្វាយ។

ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់ថ្នាំវ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាឡែហ្ស៊ី ធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេង ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាលែហ្ស៊ី អាចកើតឡើងបន្ទាប់ពីអ្នកទទួលថ្នាំបង្ការចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ (កន្ទួលកហម ហើមមុខនិងបំពង់កពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរស័ព្ទទៅ **9-1-1** ហើយនាំអ្នកជំងឺទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភ សូមទូរស័ព្ទទៅ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

Khmer translation provided by Immunize.org

ប្រតិកម្មទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង គួរតែត្រូវបានរាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) www.vaers.hhs.gov ឬទូរស័ព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) សម្រាប់តែការរាយការណ៍ប៉ុណ្ណោះ។ បុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) មិនផ្តល់ដំបូន្មានអំពីវេជ្ជសាស្ត្រទេ។*

## 6. កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។ ការទាមទារទាក់ទងនឹងរបួស ឬការស្លាប់ដោយសារការទទួលថ្នាំបង្ការ មានពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ដែលអាចមានរយៈពេលខ្លីត្រឹមពីរឆ្នាំ។ សូមចូលទៅគេហទំព័រកម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (VICP) www.hrsa.gov/vaccinecompensation ឬទូរស័ព្ទទៅលេខ **1-800-338-2382** ដើម្បីសិក្សាអំពីកម្មវិធីនិងការដាក់ពាក្យទាមទារ។

## 7. តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមចូលទៅ Food and Drug Administration (គេហទំព័ររដ្ឋបាលអាហារនិងឱសថ (FDA)) ដើម្បីទទួលបានកញ្ចប់សេវាកម្មថ្នាំបង្ការ និងព័ត៌មានបន្ថែម www.fda.gov/vaccines-blood-biologics/vaccines។
- Centers for Disease Control and Prevention (សូមទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ (CDC))៖
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636** **(1-800-CDC-INFO)** ឬ
  - ចូលមើលគេហទំព័ររបស់ CDC នៅ www.cdc.gov/vaccines។